# សេចក្តីប្រកាសអំពីការកែប្រែដាក់ពាក្យផ្តាំផ្ញើក្នុងកិច្ចប្រជុំសមាជិកគណៈកម្មការនាយកផ្នែកសិក្សាធិការ

សមាជិកគណៈកម្មការនាយកមានគម្រោងជួបជុំគ្នាផ្ទាល់ក្នុងកិច្ចប្រជុំ ប៉ុន្តែ ដោយធ្វើការប្រយ័ត្នអំពីបញ្ហារាលដាលជម្ងឺ COVID-19 គឺមានបុគ្គលិកត្រឹមតែតាមចំនួនកំណត់ប៉ុណ្ណោះ ទើបអាចចូលរួមក្នុងកិច្ចប្រជុំបាន ។ សាធារណជនអាចបើកមើលកិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការបានតាមការផ្សាយបង្ហាញភ្លាមៗនៅក្នុង lbschools.net/youtube ។ ពាក្យផ្តាំផ្ញើសាធារណៈសម្រាប់កិច្ចប្រជុំនេះ គឺនឹងធ្វើតាមការបង្ហាញនៅតាមប្រព័ន្ធទូរស័ព្ទនៃក្រសួងអប់រំ ឪស្រ្ទីគ ដូចបានរៀបរាប់នៅផ្នែកខាងក្រោម ។ សាធារណជនក៏អាចដាក់ពាក្យផ្តាំផ្ញើតាម អ៊ីម៉ែលបានដែរទៅកាន់សមាជិកគណៈកម្មការនាយកផ្ទាល់នៅពេលណាក៏បាន ដោយធ្វើការទាក់ទងនៅតាមបណ្តាញ lbschools.net/Departments/Board of Education ។ ពាក្យផ្តាំផ្ញើសាធារណៈ គឺនឹងចាក់ស្តាប់ក្នុងពេលកំពុងជួបប្រជុំ ។

គណៈកម្មការនាយកផ្នែកសិក្សាធិការទទួលស្គាល់អំពីយោបល់ពីសាធារណជន និង ជម្រុញអោយសាធារណជនដាក់ពាក្យផ្តាំផ្ញើនៅក្នុងកិច្ចប្រជុំជារៀងរាល់លើក ។

**សេចក្តីថ្លែងការណ៍ ដែលថតដាក់សម្លេងផ្ញើតាមទូរស័ព្ទ**

ពាក្យផ្តាំផ្ញើ (យោបល់) សាធារណៈតាមរយៈថតដាក់សម្លេងក្នុងទូរស័ព្ទ គឺជាកម្មសិទ្ធិសាធារណៈ នៅពេលណាសម្លេងបានទទួលការថតចូលភ្លាម ។ មានពេល បី នាទីក្នុងមួយលើកសម្រាប់ទទួលការដាក់ពាក្យផ្តាំផ្ញើពីសាធារណជន ។ បុគ្គលម្នាក់អាចដាក់ពាក្យផ្តាំផ្ញើបានតែម្តងប៉ុណ្ណោះមកលើកិច្ចការត្រូវលើកពិគ្រោះនៅក្នុងកិច្ចប្រជុំ និង ពាក្យផ្តាំផ្ញើម្តងមកលើកិច្ចការ ដែលមិនបានរាប់បញ្ចូលនៅក្នុងកិច្ចប្រជុំ ។ សូមចងចាំថា ពាក្យផ្តាំផ្ញើមកលើកិច្ចការ ដែលមិនបានរាប់បញ្ចូលនៅក្នុងកិច្ចប្រជុំ គឺមិនអាចឆ្លើយជូនបានទេនៅពេលកំពុងតែប្រជុំ ។ ប៉ុន្តែ សមាជិកគណៈកម្មការនាយកនឹងយកចិត្តស្តាប់យ៉ាងដិតដល់មកលើពាក្យផ្តាំផ្ញើទាំងអស់ ហើយពាក្យផ្តាំផ្ញើទាំងអស់នោះឯង គឺជារឿយៗ បានទទួលជាចំណែកសម្រាប់រាប់បញ្ចូលជាការពិគ្រោះទៅថ្ងៃមុខនៅក្នុងកិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការ នៅពេលមានរាយបង្ហាញជាត្រឹមត្រូវនៅក្នុងរបៀបវារៈ ។

គណៈកម្មការនាយកផ្នែកសិក្សាធិការនឹងទទួលស្តាប់មុនគេមកលើបុគ្គល ដែលចូលមកធ្វើសេចក្តីថ្លែងការណ៍ក្នុងកន្លែងផ្ទាល់ ហើយនឹងព្យាយាមទុកពេលនៅសល់សម្រាប់ទទួលស្តាប់ពាក្យផ្តាំផ្ញើតាមរយៈថតដាក់សម្លេងក្នុងទូរស័ព្ទ ។ ពាក្យផ្តាំផ្ញើទាំងអស់នឹងបញ្ជូនផ្ទាល់ទៅកាន់សមាជិកគណៈកម្មការនាយកផ្នែកសិក្សាធិការ ។

សូមមេត្តាចងចាំថា ជារឿយៗ គឺមានកុមារបើកមើលកិច្ចប្រជុំនៃគណៈកម្មការនាយកផ្នែកសិក្សាធិការ ។ ដូច្នេះ សូមប្រើពាក្យស្របទៅតាមអាយុរបស់កុមារ ។ ដោយមូលហេតុយើងធ្វើការតម្រូវសុំអោយលើកបង្ហាញថា តើពាក្យផ្តាំផ្ញើ មាន ឬ មិនមានសម្រាប់រាប់បញ្ចូលទៅក្នុងរបៀបវារៈ ហើយបើពិតដូច្នោះមែន តើមានកិច្ចការណាខ្លះ ដែលត្រូវលើកពិគ្រោះ … គឺមានតែពាក្យផ្តាំផ្ញើបានទទួល បន្ទាប់ពីរបៀបវារៈបានបិទតាំងផុតទៅប៉ុណ្ណោះ ទើបនឹងអាចចាក់ស្តាប់បាននៅក្នុងពេលកំពុងតែប្រជុំ ។ ចំពោះសាធារណជន ដែលមានចិត្តប្រាថ្នាដាក់ពាក្យផ្តាំផ្ញើតាមរយៈថតសម្លងក្នុងទូរស័ព្ទនៅពេលកំពុងតែប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការ គឺគួរប្រើតាមមធ្យោបាយដូចតទៅៈ
អោយបានទាន់ពេលថ្ងៃត្រង់ មុននឹងដល់កិច្ចប្រជុំ គឺសូមប្រើទូរស័ព្ទទាក់ទងទៅកាន់លេខ (562) 242-2190 ដើម្បីថតដាក់សម្លេងជាពាក្យផ្តាំផ្ញើរបស់អ្នក និង ធ្វើតាមអ្វីដូចបានបញ្ជាក់ប្រាប់ ។ ពាក្យផ្តាំផ្ញើទាំងអស់គួរផ្តើមធ្វើឡើងដោយរាយបង្ហាញពត៍មានដូចតទៅៈ

- ឈ្មោះរបស់អ្នក និង កិច្ចការនៅក្នុងរបៀបវារៈ ដែលអ្នកចង់អោយមានការលើកដោះស្រាយអំពី ។
- កិច្ចប្រជុំមួយណា ដែលអ្នកប្រាថ្នាអោយពាក្យផ្តាំផ្ញើរបស់អ្នកទទួលការចាក់ស្តាប់ ។

បើសិនជាការថតសម្លេងរបស់អ្នកគ្មានបង្ហាញនោះទេអំពីកិច្ចការណាមួយយ៉ាងច្បាស់លាស់នៅក្នុងរបៀបវារៈ ដែលអ្នកប្រាថ្នាអោយមានការលើកដោះស្រាយអំពី គឺវានឹងប្រើចាត់ទុកទៅកាន់ចំណែកនៃកិច្ចការមិនបានរាប់បញ្ចូលនៅក្នុងរបៀបវារៈសម្រាប់កិច្ចប្រជុំសាធារណៈ ។

បើសិនជាអ្នកមានបញ្ហា ដែលធ្វើអោយអ្នកគ្មានសមត្ថភាពបង្ហាញអំពីពាក្យផ្តាំផ្ញើរបស់អ្នកបាន ទោះជាតាមរយៈមកចូលរួមក្នុងកន្លែងប្រជុំផ្ទាល់ក្តី ឬ តាមរយៈថតដាក់សម្លេងផ្ញើក្នុងទូរស័ព្ទផ្ទាល់ក្តី សូមអញ្ជើញទាក់ទងអ្នកស្រី Leticia Rodriguez តាមលេខទូរស័ព្ទ (562) 997-8240 ។